**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៩/០៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៣

**ជូនចំពោះ**

**ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រតាមរយៈគណបក្ស សម រង្ស៊ី**

**កម្មវត្ថុ** : សំណើរបស់ឯកឧត្តម លោកជំទាវ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០០៣

ដូចកម្មវត្ថុខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យឃើញថា សំណើរបស់ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រដែលស្នើឱ្យបកស្រាយមាត្រាមួយចំនួននៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រាខ្លះនៃរដ្ឋធម្មនុញ្ញមិនបានបំពេញល័ក្ខខ័ណ្ឌនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដោយសារមានតំណាងរាស្ត្រដែលបានចុះហត្ថលេខាមិន គ្រប់ចំនួន ពីព្រោះមានតំណាងរាស្ត្រខ្លះត្រូវបានបាត់បង់សមាជិកភាពជាតំណាងរាស្ត្រដោយស្វ័យប្រវត្តិតាម បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌទី២ នៃមាត្រា ១២០ នៃព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលចែងថា " ក្នុងករណី ដែលសមាជិកគណបក្សនយោបាយមួយសុំលាលែងចេញពីគណបក្សនោះ សាមីខ្លួនត្រូវបាត់បង់សមាជិកភាព ជាតំណាងរាស្ត្រដោយស្វ័យប្រវត្តិ ។ " ។

អាស្រ័យហេតុនេះ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកសំណើរបស់ឯកឧត្តម លោកជំទាវ មក ពិនិត្យបានទេ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**